# បញ្ហាគន្លឹះ និងសំណួរដែលបានស្នើដោយ អង្គការសង្គមស៊ីវិល

## បញ្ហា

### ថវិកាសម្រាប់យេនឌ័រ

មានការពឹងពាក់ខ្លាំងពេកទៅលើអង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្តល់សេវាមូលដ្ឋាន និងអនុវត្តកម្មវិធីដើម្បីសម្រេចគោលដៅថ្នាក់ជាតិស្តីពីសមភាពយេនឌ័រ ដែលនាំឱ្យឈានទៅដល់ការអនុវត្តមិនពេញលេញ និងមិនស៊ីសង្វាក់គ្នាទៅលើផែនការសកម្មភាព។

### ការទទួលបានយុត្តិធម៌

ច្បាប់ស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ហើយករណីពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រតែងត្រូវបានដោះស្រាយក្រៅផ្លូវការ។ ពលរដ្ឋតែងមិនអាចទទួលមធ្យោបាយពីតុលាការដោយសារតែដំណើរនីតិវិធីច្បាប់មានតំលៃថ្លៃ ជំនួយផ្នែកច្បាប់មិនគ្រប់គ្រាន់ ក៏ដូចជាតុលាការមានចំនួនតិចតួចផងដែរ។

### គ្មានសមភាពនៅក្នុងច្បាប់សម្រាប់អ្នកស្រលាញ់ភេទដូចគ្នា

សហគមន៍អ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាជួបប្រទះនឹងបញ្ហាប្រឈមដ៏ធំដោយសារតែផ្នត់គំនិតអវិជ្ជមានទៅលើយេនឌ័រ។

### សុខភាពបន្តពូជ

ប្រជាជនកម្ពុជាជាច្រើន ជាពិសេសនៅតាមជនបទពុំទាន់ទទួលបានការថែទាំសុខភាពប្រកបដោយគុណភាព ឬការអប់រំអំពីសិទ្ធិសុខភាពបន្តពូជ និងផ្លូវភេទនោះទេ។

### ការងារ

ចំនួនថ្នាក់ដឹកនាំសហជីពជាស្ត្រីនៅមានតិច។ក្រៅពីនេះការប្រើកិច្ចសន្យារយៈពេលខ្លីធ្វើឱ្យប៉ះពាល់ដល់ស្ត្រី និងស្ត្រីកម្មករជាច្រើននៅក្នុងឧស្សាហកម្មវាយនភណ្ឌធ្លាប់ទទួលរងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ។

## សំណួរ

### ស្ត្រីក្នុងភាពជាអ្នកដឹកនាំ

តើប្រទេសកម្ពុជានឹងបង្កើតកូតាដើម្បីបង្កើនភាពជាតំណាងរបស់ស្ត្រីនៅក្នុងមុខតំណែងជាអ្នកសម្រេចចិត្តដែរ ឬទេ?

### ការទទួលបានការអប់រំ

តើរាជរដ្ឋាភិបាលកម្ពុជានឹងធ្វើឱ្យការអប់រំជាកាតព្វកិច្ចសម្រាប់កុមារគ្រប់រូបដែរឬទេ?

### អំពើហិង្សាទាក់ទងនឹងយេនឌ័រដែលធ្វើឡើងដោយភ្នាក់ងាររដ្ឋ

តើរាជរដ្ឋាភិបាលកម្ពុជានឹងចាត់វិធានការអ្វីខ្លះដើម្បីធានាថាកងកម្លាំងនគរបាល កងកម្លាំងយោធា និងកងកម្លាំងសន្តិសុខទាំងអស់ត្រូវបានបណ្តុះបណ្តាលអំពីយុទ្ធសាស្ត្រ ដើម្បីជៀសវាងអំពើហិង្សានៅពេលធ្វើការប្រាស្រ័យទាក់ទងជាមួយជនស៊ីវិល ជាពិសេសជាមួយស្ត្រី?

### កង្វះសេវាកម្មសម្រាប់ជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ

តើរាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់ជំនួយថវិកាសម្រាប់សេវាទូរសព្ទបន្ទាន់ដើម្បីរាយការណ៍អំពីអំពើហិង្សាដើម្បីធានាថាស្ត្រី និងក្មេងស្រីនៅសហគមន៍ជនបទអាចទទួលបានជំនួយ និងព័ត៌មានទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រដែរ ឬទេ?

### ស្ត្រី និងកុមារនៅក្នុងពន្ធនាគារ

តើរាជរដ្ឋាភិបាលកម្ពុជាមានផែនការអ្វីខ្លះក្នុងការកាត់បន្ថយការឃុំខ្លួនបណ្តោះអាសន្នជាទូទៅ ហើយលុបបំបាត់ការឃុំឃាំងស្ត្រីមានផ្ទៃពោះ និងកុមារ?

### ការងារ

តើអ្វីជាទណ្ឌកម្មដែលមានជាធរមានដើម្បីហាមឃាត់ការរំលោភបំពាននៃការរើសអើងដោយផ្អែកលើមាតុភាព?

ឧបត្ថម្ភដោយ
EUROPEAN UNION

ផលិតដោយ
DCA actalliance
VOICES for GENDER EQUALITY
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

@CCHRCambodia @CCHRCambodia @EU.Cambodia

CC BY NC SA

ខែមិថុនា ឆ្នាំ២០២០